# ផ្នែកទី III

# គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ

## ( Arrows Markings )

គំនូសសញ្ញា ព្រួញលើទ្រូងផ្លូវ ( ជាទូទៅលើគន្លងផ្លូវ )មានពណ៌ស សំរាប់អោយអ្នកបើកបរ ធ្វើចរាចរទៅតាមទិសដៅ ដែលចង្អុលប្រាប់របស់ព្រួញ ។ គំនូសសញ្ញានេះ ប្រើនៅពេលខិតជិតដល់ផ្លូវប្រសព្វ ឬ នៅពេលខិតជិតដល់គន្លងផ្លូវដែល រួមចូលទៅគន្លងផ្សេង ដើម្បីអោយអ្នកបើកបរ ដឹងជាមុន ងាយស្រួលប្តូរគន្លងផ្លូវ ទៅតាមទិសដែលខ្លួនចង់ទៅ ។

# ផ្នែកទី III : គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ ( Arrows Markings )



## គំនូសសញ្ញាព្រួញទៅមុខត្រង់

STRAIGTH ARROW

**លេខកូដ :PW03-M3-01**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស ទៅមុខត្រង់ ប្រើសំរាប់អោយ អ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវ នេះ សំរាប់ធ្វើ ចរាចរទៅមុខត្រង់ តែប៉ុណ្ណោះ ។



## គំនូសសញ្ញាព្រួញទៅមុខត្រង់ និង បត់ស្តាំ

TURN RIGHT AND STRAIGTH ARROW

**លេខកូដ :PW03-M3-02**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស ទៅមុខត្រង់ និង បត់ស្តាំ ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរទៅមុខត្រង់ និង បត់ទៅស្តាំ តែប៉ុណ្ណោះ ។



## គំនូសសញ្ញាព្រួញទៅមុខត្រង់ និង បត់ឆ្វេង

TURN LEFT AND STRAIGTH ARROW

**លេខកូដ :PW03-M3-03**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស ទៅមុខត្រង់ និង បត់ឆ្វេង ប្រើសំរាប់អោយអ្នកបើកបរដឹងថា
នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរទៅមុខត្រង់ និង បត់ទៅ ឆ្វេង តែប៉ុណ្ណោះ ។



## គំនូសសញ្ញាព្រួញ បត់ស្តាំ

TURN RIGHT ARROW

**លេខកូដ :PW03-M3-04**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស បត់ទៅខាងស្តាំ ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរ បត់ទៅស្តាំ តែប៉ុណ្ណោះ ។



### គំនូសសញ្ញាព្រួញ បត់ឆ្វេង
TURN LEFT ARROW

**លេខកូដ :PW03-M3-05**

**ខ្លឹមសារ :** គំនូសសញ្ញាព្រួញពណ៌ស បត់ទៅខាងឆ្វេង ប្រើសំរាប់អោយអ្នកបើកបរដឹងថា នៅត្រង់ផ្លូវប្រសព្វខាងមុខ គន្លងផ្លូវនេះសំរាប់ធ្វើចរាចរ បត់ទៅឆ្វេង តែប៉ុណ្ណោះ ។

---



### គំនូសសញ្ញាព្រួញ ងាកស្តាំ
**(នៅចន្លោះគំនូសទោល ដាច់ៗ បែងចែកទិសចរាចរ)**
KEEP RIGHT ARROW

**លេខកូដ :PW03-M3-06**

**ខ្លឹមសារ :** គំនូសសញ្ញា ព្រួញពណ៌សងាកស្តាំ ដែលនៅចន្លោះគំនូសទោលដាច់ៗ ពណ៌លឿង ប្រើសំរាប់អោយដំណឹងថា នៅខាងមុខមានគំនូសជាប់ (ទោល ឬ ភ្លោះ ) ពណ៌លឿង ។ អ្នកបើកបរ បើឃើញគំនូសសញ្ញានេះ ត្រូវងាកមកគន្លងខាងស្តាំតាមគំនូសសញ្ញាព្រួញនេះ ។

---



### គំនូសសញ្ញាព្រួញ ងាកស្តាំ (លើគន្លងផ្លូវ )
KEEP RIGHT ARROW

**លេខកូដ :PW03-M3-07**

**ខ្លឹមសារ :** គំនូសសញ្ញា ព្រួញពណ៌សងាកស្តាំ នៅលើគន្លងផ្លូវប្រើសំរាប់អោយដំណឹងថា នៅខាងមុខ គន្លងផ្លូវនេះ នឹងរួមចូលទៅ គន្លងផ្លូវខាងស្តាំតែមួយ ។

---



### គំនូសសញ្ញាព្រួញ ងាកឆ្វេង (លើគន្លងផ្លូវ )
KEEP LEFT ARROW

**លេខកូដ :PW03-M3-08**

**ខ្លឹមសារ :** គំនូសសញ្ញា ព្រួញពណ៌សងាកឆ្វេង នៅលើគន្លងផ្លូវប្រើសំរាប់អោយដំណឹងថា នៅខាងមុខ គន្លងផ្លូវនេះ នឹងរួមចូលទៅ គន្លងផ្លូវខាងឆ្វេងតែមួយ ។